ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
អគ្គលេខាធិកាដ្ឋាន គ.ជ.ភ១.ផ១.
លេខ...១១៦...គ.ជ.ភ១.ផ១.

ថ្ងៃ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី...2...ខែ...សីហា...ឆ្នាំ២០២១

# របាយការណ៍សមិទ្ធផលសំខាន់ៗ រយៈពេល៥ឆ្នាំ (២០១៧-២០២១) របស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ

## ១.សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រធាន និង **សម្តេចវិបុលបញ្ញា សុខ អាន** ជាអនុប្រធាន។ នៅឆ្នាំ២០១៣ ការងារជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានរាជរដ្ឋាភិបាលសម្រេចធ្វើសមាហរណកម្មឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដោយមាន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ជាប្រធាន។ ជាបន្តបន្ទាប់ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិនេះក៏ត្រូវបានធ្វើវិសោធនកម្ម ដោយកែសម្រួលមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ បន្ទាប់ពីគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ។

## ២.សមិទ្ធផលការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានក១.ផ១ រយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧-២០២៣)

### ២.១. ការងាររៀបចំឯកសារគតិយុត្ត ឯកសារគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រនានា

- បានរៀបកែសម្រួល និងបង្កើតឯកសារគតិយុត្តិមួយចំនួនឲ្យស្របតាមស្ថានភាពការងារប្រចាំថ្ងៃ
  - ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រាទី១ និងមាត្រាទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
  - អនុក្រឹត្យលេខ ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ


ទីស្តីការគណៈរដ្ឋមន្ត្រី មហាវិថីសហព័ន្ធរុស្ស៊ី, ប្រអប់សំបុត្រលេខ ៖ 2470, ទូរស័ព្ទ 023 212 432 / 023 224 629 Website : www.card.gov.kh

-សេចក្ដីសម្រេចលេខ៩៩ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

-សេចក្ដីសម្រេចលេខ០៥ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

-ប្រកាសលេខ ៥២ ប្រក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

-បានដឹកនាំ និងបង្កើតក្រុមការងារបច្ចេកទេសជំរុញចលនាភូមិមួយផលិតផលមួយ ចំនួន១០ក្រសួង រួមមានក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រសួងពត៌មាន ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍

-បានដឹកនាំ និងបង្កើតគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១រាជធានី-ខេត្ត ចំនួន២៥ខេត្ត-រាជធានី

-បានដឹកនាំ និងបង្កើតក្រុមការងារដឹកនាំ សម្របសម្រួលការងារចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ ចំនួន០៤ក្រសួង រួមមានក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍

-បានរៀបចំឯកសារគោលនយោបាយជាតិស្ដីពី ការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦

-បានរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ៥ឆ្នាំ លើកទី១ ២០១៩ - ២០២៣

-បានរៀបចំគោលការណ៍ណែនាំស្ដីពីការចងក្រងសមាជិកចលនាភូមិ១ផលិតផល១

-បានរៀបចំប្រកាសលេខ ០៧០ ភ១.ផ១. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

## ២.២. ការងាររៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ

- ផ្អែកតាមសេចក្ដីជូនដំណឹងលេខ ៤៧៩ ស.ជ.ណ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ បានរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ**ថ្ងៃទី៩ មេសា** ជារៀងរាល់ឆ្នាំ បានចំនួន០៤លើក និងរៀបចំឱ្យមានគោលការណ៍រួម ស្ដីពីការរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរនៅទូទាំងប្រទេស។

-លើកទី១ ឆ្នាំ២០១៨ ក្រោមប្រធានបទ “**យើងនាំប្រើប្រាស់ផលិតផលខ្មែរ**”

-លើកទី២ ឆ្នាំ២០១៩ ក្រោមប្រធានបទ "**យើងនាំគ្នាគាំទ្រ និងប្រើប្រាស់ផលិតផលខ្មែរ**"

-លើកទី៣ ឆ្នាំ២០២០ ក្រោមប្រធានបទ "**លើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ គឺលើកកម្ពស់ការផលិត វត្ថុធាតុដើមកែច្នៃ និងទិញផលិតផលខ្មែរ**"

-លើកទី៤ ឆ្នាំ២០២១ ក្រោមប្រធានបទ "**រួមគ្នាទិញនិងប្រើប្រាស់ផលិតផលខ្មែរ គឺរួមគ្នាលើកកម្ពស់កិត្យានុភាពជាតិ**"

## ២.៣. ការងារចងក្រងផលិតផលភូមិមួយផលិតផលមួយ

- បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត ក្នុងការងារប្រមូលចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ នៅទូទាំងប្រទេស ដោយគិតនៅឆ្នាំ២០២១នេះ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយបានចងក្រងផលិតផលភូមិមួយផលិតផលមួយបានចំនួន ១២០មុខ ដែលក្នុងនោះជាផលិតផលដ៏មានសក្តានុពលរបស់ខេត្តចំនួន១០ រួមមានខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តព្រៃវែងនិងខេត្តសៀមរាប។

## ២.៤. ការងាររៀបចំព្រឹត្តិការកម្រិតជាតិ អន្តរជាតិ និងពិព័រណ៍ផលិតផលខ្មែរ

- បានសហការយ៉ាងជិតស្និតជាមួយក្រសួងពាណិជ្ជកម្ម វិស័យឯកជននានា ក្នុងការរៀបចំតាំងពិព័រណ៍ផលិតផលខ្មែរ ផលិតផលភូមិមួយផលិតផលមួយ នៅតាមបណ្តារាជធានី-ខេត្តទូទាំង២៥ ព្រមទាំងចូលរួមព្រឹត្តិការណ៍ពិព័រណ៍កម្រិតថ្នាក់ជាតិ និងអន្តរជាតិជាច្រើនផងដែរ។

## ២.៥. ការងារកសាងសមត្ថភាព និងបណ្តុះបណ្តាល

- បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញនិងសហគ្រិនភាពដល់អាជីវករ សិប្បករ កសិករ សេវាករ នៅតាមបណ្តារាជធានី ខេត្តទាំង២៥។
- បានរៀបចំបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋានភ១.ផ១ ទៅចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិនានា ជារៀងរាល់ឆ្នាំ។

## ២.៦. ការងារកិច្ចសហប្រតិបត្តិការបរទេស វិស័យឯកជន និងសង្គមស៊ីវិល

- បានសហការជាមួយទីភ្នាក់ងារសហប្រតិបត្តការអន្តរជាតិថៃ (TICA) លើគម្រោងសាងសង់មជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ នៅខេត្តកំពង់ចាម ដែលគ្រោងនឹងចាប់ផ្តើមដំណើការសាងសង់នាពេលឆាប់ៗខាងមុខនេះនៅលើផ្ទៃដី ២.៤ ហិកតា។
- បានសហការ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងវិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសិក្សាស្រាវជ្រាវ ក្នុងគោលបំណងរួមគ្នាលើកកម្ពស់ចលនាភូមិមួយ ផលិតផលមួយ នៅកម្ពុជា ÷

-កិច្ចព្រមព្រៀងទ្វេភាគីជាមួយសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ

-កិច្ចព្រមព្រៀងទ្វេភាគីជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម

-កិច្ចព្រមព្រៀងទ្វេភាគីជាមួយរាជបណ្ឌិត្យសភាកម្ពុជា

**២.៧. ការងារផ្សព្វផ្សាយ ចែករំលែកព័ត៌មាន និងចំណេះដឹង**

- បានបង្កើតវេបសាយរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ អាស័យដ្ឋាន www.ovopnationalcommittee.gov.kh
- បានបង្កើត Facebook Page របស់អគ្គលេខាធិការដ្ឋានភ១.ផ១ ដែលមានឈ្មោះ OVOP National Committee Cambodia ដែលបច្ចុប្បន្នមានចំនួន 1,802like និង1,843 follow និងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់ view ក្នុងមួយ post
- បានបង្កើត Channel Telegram ដែលមានឈ្មោះ OVOP National Committee Cambodia ដែលមានចំនួនសមាជិក២៣២ចុះឈ្មោះនិងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់ view ក្នុងមួយ post
- បានបង្កើតក្រុមការងារភ១.ផ១ អន្តរក្រសួងតាមរយៈគ្រុប Telegram ដើម្បីងាយស្រួលទំនាក់ទំនង និងចែករំលែកព័ត៌មាន
- បានបង្កើតក្រុមការងារលេខាធិការដ្ឋានភ១.ផ១ រាជធានីខេត្ត តាមរយៈគ្រុប Telegram ដើម្បីងាយស្រួលទំនាក់ទនង និងចែករំលែកពតិមាន
- បានបង្កើតបណ្តាញក្រុមការងារជាច្រើនទៀតជាមួយក្រុមអាជីវករ សិប្បករ សមាគម សហគមន៍ អ្នកផ្តល់សេវា និងក្រុមការងារនិស្សិតជាដើម

**៣. សេចក្តីសន្និដ្ឋាន**

សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ រយៈពេល០៥ឆ្នាំ (ឆ្នាំ២០១៧-ឆ្នាំ២០២១) ទទួលបានជោគជ័យ និងបានឆ្លើយតបទៅនឹងការខិតខំធ្វើឱ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ។ ទោះបីយ៉ាងណាក៏ដោយ ការសម្រេចការងារនេះគឺពឹងផ្អែកទាំងស្រុងលើការខិតខំយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ភ១.ផ១ ព្រមទាំងបានចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយ រាជធានី-ខេត្ត។

**ត.ប ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ**

**អគ្គលេខាធិការ**

**វេជ្ជ.ជា_សំណាង**